# ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ និងការធ្វើរបាយការណ៍

បាត់ដំបង ថ្ងៃទី២១-២២ ខែកញ្ញា ឆ្នាំ២០១៥

## គំនូសបំព្រួញនៃការថែទាំជំនួសចំពោះកុមាររងគ្រោះ និងងាយរងគ្រោះ និងការធ្វើអធិការកិច្ច



## ១. ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ

ក្រសួង សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សហការជាមួយ លេខាធិការដ្ឋាន គ.ជ.អ.ប ក្រុមប្រឹក្សាខេត្តបាត់ដំបង ក្រុមប្រឹក្សាក្រុង ស្រុក និងក្រុមប្រឹក្សាឃុំ សង្កាត់ និងផ្នែកពាក់ព័ន្ធ នឹងធ្វើការតាមដានត្រួតពិនិត្យ និងវាយតម្លៃ លើការអនុវត្តមុខងាររបស់រដ្ឋបាលខេត្តបាត់ដំបង រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ ដើម្បីប្រមូលព័ត៌មាន និងបទពិសោធន៍ ក្នុងដំណាក់កាលនៃការអនុវត្តសាកល្បងផ្ទេរមុខងារ។

### ៣.១. ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

- សហការជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប និងផ្នែកពាក់ព័ន្ធធ្វើការតាមដានត្រួតពិនិត្យលើការអនុវត្តមុខងាររបស់រដ្ឋបាលខេត្តបាត់ដំបង រដ្ឋបាលក្រុងស្រុក និងរដ្ឋបាលឃុំសង្កាត់ប្រចាំខែ និងត្រីមាស ដោយផ្អែកលើរបាយការណ៍បូកសរុប របស់រដ្ឋបាលនីមួយៗ
- សហការជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប និងផ្នែកពាក់ព័ន្ធធ្វើការវាយតម្លៃលើការអនុវត្តមុខងារទាំងបីរបស់រដ្ឋបាលខេត្តបាត់ដំបង រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ប្រចាំត្រីមាស ប្រចាំឆមាស និងនៅពេលបញ្ចប់ការអនុវត្តសាកល្បងផ្ទេរមុខងារ

### ៣.២. ក្រុមប្រឹក្សាខេត្តបាត់ដំបង

- ពិនិត្យរបាយការណ៍អនុវត្តមុខងាររបស់រដ្ឋបាលខេត្តដើម្បីកែលម្អ និងផ្តល់អនុសាសន៍
- ចុះតាមដានត្រួតពិនិត្យលើការអនុវត្តមុខងាររបស់រដ្ឋបាលខេត្ត

### ៣.៣. មន្ទីរ ស.អ.យ ខេត្តបាត់ដំបង

- តាមដានការអនុវត្តមុខងាររបស់រដ្ឋបាលខេត្ត រដ្ឋបាលក្រុងស្រុក និងរដ្ឋបាលឃុំសង្កាតដើម្បីផ្ទៀងផ្ទាត់ជាមួយសៀវភៅណែនាំ
- សហការជាមួយក្រុមការងារបច្ចេកទេសវិមជ្ឈការ និងវិសហមជ្ឈការរបស់ក្រសួង ស.អ.យ និងលេខាធិការដ្ឋាន គ.ជ.អ.ប ដើម្បីចុះតាមដានត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តមុខងាររបស់រដ្ឋបាលខេត្តបាត់ដំបង រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់

### ៣.៤. ក្រុមប្រឹក្សាក្រុង ស្រុក

- ពិនិត្យរបាយការណ៍អនុវត្តមុខងាររបស់រដ្ឋបាលក្រុង ស្រុកដើម្បីកែលម្អ និងផ្តល់អនុសាសន៍
- ចុះតាមដានត្រួតពិនិត្យលើការអនុវត្តមុខងាររបស់រដ្ឋបាលក្រុង ស្រុក

### ៣.៥. ការិយាល័យ ស.អ.យ ក្រុង ស្រុក

- តាមដានការអនុវត្តមុខងាររបស់រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ដើម្បីផ្ទៀងផ្ទាត់ជាមួយសៀវភៅណែនាំ
- សហការជាមួយក្រុមការងារបច្ចេកទេសវិមជ្ឈការ និងវិសហមជ្ឈការរបស់ក្រសួងស.អ.យ និងលេខាធិការដ្ឋាន គ.ជ.អ.ប ដើម្បីចុះតាមដានត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តមុខងាររបស់រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់

៣.៦. ក្រុមប្រឹក្សាឃុំ សង្កាត់

- ពិនិត្យរបាយការណ៍អនុវត្តមុខងាររបស់រដ្ឋបាលឃុំ សង្កាត់ដើម្បីកែលម្អ និងផ្តល់អនុសាសន៍
- ចុះតាមដានត្រួតពិនិត្យលើការអនុវត្តមុខងាររបស់រដ្ឋបាលឃុំ សង្កាត់

# ២.ការធ្វើរបាយការណ៍

## ២.១. រដ្ឋបាលខេត្ត

ធ្វើរបាយការណ៍បូកសរុបលទ្ធផលការអនុវត្តមុខងារប្រចាំខែ ត្រីមាស និងឆ្នាំជូន ក្រុមប្រឹក្សាខេត្តបាត់ដំបង និងផ្ញើជូនក្រសួង ស.អ.យ តាមរយៈមន្ទីរ ស.អ.យ ខេត្តបាត់ដំបង

របាយការណ៍ខេត្ត.docx

## ២.២. រដ្ឋបាលក្រុង ស្រុក

ធ្វើរបាយការណ៍ពីលទ្ធផលអនុវត្តមុខងារ ប្រចាំខែ ត្រីមាស និងឆ្នាំជូនក្រុមប្រឹក្សាក្រុង ស្រុក និងផ្ញើជូនក្រសួង ស.អ.យ តាមរយៈការិយាល័យ ស.អ.យ និងមន្ទីរ ស.អ.យ

របាយការណ៍ក្រុង ស្រុក.docx

## ២.៣. រដ្ឋបាលឃុំ សង្កាត់

ធ្វើរបាយការណ៍ពីលទ្ធផលអនុវត្តមុខងារ ប្រចាំខែ ត្រីមាស និងឆ្នាំជូនក្រុមប្រឹក្សាឃុំ សង្កាត់ និងផ្ញើជូនក្រសួង ស.អ.យ តាមរយៈការិយាល័យ ស.អ.យ និងមន្ទីរ ស.អ.យ

របាយការណ៍ឃុំ សង្កាត់.docx

២.៤. ការិយាល័យ ស.អ.យ ក្រុង ស្រុក

ជួយរដ្ឋបាលក្រុង ស្រុក ធ្វើរបាយការណ៍អនុវត្តមុខងារប្រចាំខែ ត្រីមាស និងឆ្នាំ

២.៤. មន្ទីរ ស.អ.យ ខេត្ត

- ជួយរដ្ឋបាលខេត្តបាត់ដំបង ធ្វើរបាយការណ៍បូកសរុបការអនុវត្តមុខងារប្រចាំខែ ត្រីមាស និងប្រចាំឆ្នាំ
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលការអនុវត្តមុខងារទាំងបីប្រចាំខែ ត្រីមាស និងឆ្នាំរបស់រដ្ឋបាលខេត្តបាត់ដំបង រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ផ្ញើជូន ក្រសួង ស.អ.យ

របាយការណ៍មន្ទីរ.docx

# សូមអរគុណ!